ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ
លេខ: ៨៤០ សវណ

រាជធានីភ្នំពេញថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ២០១៧

## សូមជម្រាបជូន
## ឯកឧត្តមអភិបាល នៃគណៈអភិបាលរាជធានី ខេត្ត

**កម្មវត្ថុ** ÷ ស្តីពីការប្រកាសទ្រព្យសម្បត្តិ និងបំណុលរបស់សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី៤។

**យោង** ÷ -ព្រះរាជក្រមលេខ នស/រកម/០៤១០/០០៤ ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ២០១០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ។

-សេចក្តីណែនាំលេខ ០១៩ សណន ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១២ ស្តីពីការប្រកាសទ្រព្យសម្បត្តិ និងបំណុលរបស់សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូនឯកឧត្តមថា ច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការប្រឆាំងអំពើពុករលួយ បានតម្រូវឲ្យសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ដែលជាមន្ត្រីសាធារណៈមានអាណត្តិជ្រើសតាំងដោយការបោះឆ្នោត ត្រូវធ្វើការប្រកាសទ្រព្យសម្បត្តិ និងបំណុលរបស់ខ្លួនស្របតាមគោលការណ៍ និងពេលវេលាកំណត់។

ក្នុងគោលបំណងឲ្យសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី៤នេះ មានមូលដ្ឋាន និងមានភាពងាយស្រួលក្នុងការអនុវត្តការប្រកាសទ្រព្យសម្បត្តិ និងបំណុលរបស់ខ្លួន បានត្រឹមត្រូវ និងទាន់ពេលវេលាស្របតាមការកំណត់ក្នុងមាត្រា១៧ និងមាត្រា១៨ នៃច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ ក្រុមជនបង្គោលប្រឆាំងអំពើពុករលួយក្រសួងមហាផ្ទៃផ្នែករដ្ឋបាលស៊ីវិល សូមធ្វើការណែនាំអំពីការប្រកាសទ្រព្យសម្បត្តិ និងបំណុលរបស់សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី៤ ដូចខាងក្រោម ៖

១- ក្រុមជំនួយការក្រុមជនបង្គោលប្រឆាំងអំពើពុករលួយរបស់រាជធានី ខេត្តនីមួយៗ ត្រូវធ្វើការផ្សព្វផ្សាយ និងណែនាំដល់គ្រប់រដ្ឋបាលក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ អំពីខ្លឹមសារសេចក្តីណែនាំលេខ ០១៩ សណន ដូចមានចុះក្នុងយោងខាងលើ ដើម្បីឲ្យសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី៤ ធ្វើការប្រកាសទ្រព្យសម្បត្តិ និងបំណុលរបស់ខ្លួនបន្ទាប់ពីដំណើរការកិច្ចប្រជុំប្រកាសសុពលភាពរួចហើយ។

២-រដ្ឋបាលក្រុង ស្រុក ខណ្ឌនីមួយៗ ត្រូវថតចម្លងសេចក្តីណែនាំលេខ ០១៩ សណន ដូចមានភ្ជាប់ជូនមកជាមួយនេះ ជូនដល់ក្រុមប្រឹក្សាឃុំ សង្កាត់ទាំងអស់នៅថ្ងៃបើកកិច្ចប្រជុំដំបូង រួចឲ្យអធិបតីនៃអង្គប្រជុំធ្វើការផ្សព្វផ្សាយ និងណែនាំឲ្យសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ដែលត្រូវជាប់កាតព្វកិច្ចប្រកាសទ្រព្យសម្បត្តិ និងបំណុល ឲ្យរៀបចំឯកសារប្រកាសទ្រព្យសម្បត្តិ និងបំណុលរបស់ខ្លួន ឲ្យបានតាមគោលការណ៍ និងពេលវេលាដែលបានកំណត់នៅក្នុងច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ និងសេចក្តីណែនាំលេខ ០១៩ សណនខាងលើនេះ។

៣-ចំពោះឯកសារទម្រង់បែបបទនៃការប្រកាសទ្រព្យសម្បត្តិ និងបំណុល អាចទាញយកបានពីក្នុងគេហទំព័ររបស់អង្គភាពប្រឆាំងអំពើពុករលួយ www.acu.gov.kh ។ រាជធានី ខេត្តនីមួយៗ ត្រូវថតចម្លងទម្រង់បែបបទនៃការប្រកាសទ្រព្យសម្បត្តិ និងបំណុល ដែលបានទាញចេញពីគេហទំព័រ ឬដែលបានភ្ជាប់ជូនមកជាមួយនេះ ជូនដល់រដ្ឋបាលក្រុង ស្រុក ខណ្ឌទាំងអស់របស់ខ្លួន ដើម្បីចាត់ចែងថតចម្លងបញ្ជូនទៅក្រុមប្រឹក្សាប្រឹក្សាឃុំ សង្កាត់ ក្នុង០១ឃុំ សង្កាត់ ចំនួន ០១ច្បាប់។ សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ដែលជាប់កាតព្វកិច្ចត្រូវប្រកាសទ្រព្យសម្បត្តិ និងបំណុល ត្រូវទទួលខុសត្រូវ និងម្ចាស់ការថតចម្លងទម្រង់បែបបទនៃការប្រកាសទ្រព្យសម្បត្តិ និងបំណុលនេះដោយខ្លួនឯង។

៤-ទីចាត់ការគ្រប់គ្រងធនធានមនុស្សសាលារាជធានី ខេត្ត ត្រូវដើរតួនាទីជាសេនាធិការឲ្យក្រុមជំនួយការក្រុមជនបង្គោលប្រឆាំងអំពើពុករលួយរាជធានី ខេត្ត ដើម្បីគាំទ្រ សម្របសម្រួល និងជំរុញឲ្យសមាជិកក្រុមប្រឹក្សាអាណត្តិទី៤ ដែលមានកាតព្វកិច្ចត្រូវប្រកាសទ្រព្យសម្បត្តិ និងបំណុល ឲ្យរួសរាន់ធ្វើការប្រកាសទ្រព្យសម្បត្តិ និងបំណុលរបស់ខ្លួន ស្របតាមគោលការណ៍ និងពេលវេលាដែលបានកំណត់។

៥-ចំពោះឯកសារប្រកាសទ្រព្យសម្បត្តិ និងបំណុលរបស់សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ដែលបានបំពេញរួចហើយ សាមីខ្លួនអាចបញ្ជូនឯកសាររបស់ខ្លួនទៅអង្គភាពប្រឆាំងអំពើពុករលួយដោយផ្ទាល់ ឬអាចបញ្ជូនមកទីចាត់ការគ្រប់គ្រងធនធានមនុស្សសាលារាជធានី ខេត្តសាមីតាមរយៈរដ្ឋបាលក្រុង ស្រុក ខណ្ឌរបស់ខ្លួន ដើម្បីចាត់ចែងបញ្ជូនបន្តមកអង្គភាពប្រឆាំងអំពើពុករលួយ ឲ្យបានទាន់ពេលវេលាកំណត់។ ទន្ទឹមនោះ ក្រុមជំនួយការក្រុមជនបង្គោលប្រឆាំងអំពើពុករលួយរាជធានី ខេត្តនីមួយៗ ត្រូវរៀបចំរបាយការណ៍បញ្ជូនមកក្រុមជនបង្គោលប្រឆាំងអំពើពុករលួយផ្នែករដ្ឋបាលស៊ីវិលក្រសួងមហាផ្ទៃ ពាក់ព័ន្ធនឹងដំណើរការប្រកាសទ្រព្យសម្បត្តិ និងបំណុលរបស់សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី៤នេះ។

អាស្រ័យហេតុនេះ សូមឯកឧត្តមជ្រាប និងចាត់ចែងអនុវត្តតាមការគួរ។

សូមឯកឧត្តមមេត្តាទទួលនូវសេចក្តីរាប់អានដ៏ជ្រាលជ្រៅអំពីខ្ញុំ។

**រដ្ឋលេខាធិការ និងជាប្រធាន**

**ក្រុមជនបង្គោលប្រឆាំងអំពើពុករលួយផ្នែករដ្ឋបាលស៊ីវិល**

សក់ សេដ្ឋា

**ចម្លងជូន ៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមុខងារសាធារណៈ
- អង្គភាពប្រឆាំងអំពើពុករលួយ
- ខុទ្ទកាល័យសម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ( ដើម្បីជូនជ្រាបជាព័ត៌មាន )
- ឯកសារ កាលប្បវត្តិ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ
លេខ : ០១៩ សណាន

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ២០១២

# សេចក្តីណែនាំ
## ស្តីពី
## ការប្រកាសទ្រព្យសម្បត្តិ និងបំណុលរបស់សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់

យោងព្រះរាជក្រមលេខ នស/រកម/០៤១០/០០៤ ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ២០១០ ស្តីពីការប្រកាសឲ្យប្រើច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ។

យោងសេចក្តីសម្រេចលេខ ០០៣/១១ ល.ស អ.ប.ព ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០១១ របស់អង្គភាពប្រឆាំងអំពើពុករលួយ ស្តីពីទម្រង់បែបបទ និងនីតិវិធីនៃការប្រកាសទ្រព្យសម្បត្តិ និងបំណុល។

យោងប្រកាសលេខ ១០៤ ប្រ.ក ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០១១ ស្តីពីការបង្កើតក្រុមជនបង្គោលប្រឆាំងអំពើពុករលួយរបស់ក្រសួងមហាផ្ទៃ។

យោងលិខិតលេខ ០៤១/១២ ល.ស អ.ប.ព ចុះថ្ងៃទី០៩ ខែមេសា ឆ្នាំ២០១២ របស់អង្គភាពប្រឆាំងអំពើពុករលួយ ស្តីពីសេចក្តីបំភ្លឺពីការប្រកាសទ្រព្យសម្បត្តិ និងបំណុលសម្រាប់អ្នកលាលែងដោយកាតព្វកិច្ចច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ និងការកំណត់ជាទូទៅមួយចំនួនសម្រាប់ប្រកាសទ្រព្យសម្បត្តិ និងបំណុលលើកទី២។

ក្រសួងមហាផ្ទៃ សូមធ្វើការណែនាំអំពីការប្រកាសទ្រព្យសម្បត្តិ និងបំណុលរបស់សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ដូចខាងក្រោម ៖

### ១. សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ជាប់ឆ្នោតឡើងវិញសម្រាប់អាណត្តិថ្មី

ចំពោះសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ណា ដែលធ្លាប់បានជាប់ឆ្នោតជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងអាណត្តិមុន ហើយបានជាប់ឆ្នោតឡើងវិញជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងអាណត្តិថ្មី ត្រូវអនុវត្តការប្រកាសទ្រព្យសម្បត្តិ និងបំណុលតាមរបបប្រកាស០២ឆ្នាំម្តង។

ប្រកាសទ្រព្យសម្បត្តិ និងបំណុលតាមរបបប្រកាស០២ឆ្នាំម្តង ត្រូវដំណើរការតាមកាលបរិច្ឆេទដូចខាងក្រោម ៖

| ប្រសិនបើប្រកាសទ្រព្យសម្បត្តិ និងបំណុលលើកដំបូងនៅក្នុងថ្ងៃណាមួយ ( គិតថ្ងៃយកឯកសារប្រកាសមកដល់ អ.ប.ព ) ក្នុងឆ្នាំ | ត្រូវប្រកាសទ្រព្យសម្បត្តិ និងបំណុលលើកទី២ នៅថ្ងៃទី | ត្រូវប្រកាសទ្រព្យសម្បត្តិ និងបំណុលលើកទី៣ នៅថ្ងៃទី | ត្រូវប្រកាសទ្រព្យសម្បត្តិ និងបំណុលលើកទី៤ នៅថ្ងៃទី |
|---|---|---|---|
| ឆ្នាំ២០១១ | ១-៣១ មករា ២០១៣ | ១-៣១ មករា ២០១៥ | ១-៣១ មករា ២០១៧ |
| ឆ្នាំ២០១២ | ១-៣១ មករា ២០១៤ | ១-៣១ មករា ២០១៦ | ១-៣១ មករា ២០១៨ |

| | | | |
|---|---|---|---|
| ឆ្នាំ២០១៣ | ១-៣១ មករា ២០១៥ | ១-៣១ មករា ២០១៧ | ១-៣១ មករា ២០១៩ |
| ឆ្នាំ២០១៤ | ១-៣១ មករា ២០១៦ | ១-៣១ មករា ២០១៨ | ១-៣១ មករា ២០២០ |
| ឆ្នាំ២០១៥ | ១-៣១ មករា ២០១៧ | ១-៣១ មករា ២០១៩ | ១-៣១ មករា ២០២១ |

**សម្គាល់** ៖ ទ្រព្យសម្បត្តិ និងបំណុលដែលមានក្រោយថ្ងៃទី០៧ ខែមេសា ឆ្នាំ២០១១ (ថ្ងៃកំណត់ចុងក្រោយនៃការប្រកាសទ្រព្យសម្បត្តិដំបូង) ត្រូវប្រាប់ពីប្រភពនៃទ្រព្យសម្បត្តិនោះ។

## ២. សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ដែលមិនជាប់ឆ្នោតឡើងវិញសម្រាប់អាណត្តិថ្មី

ចំពោះសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ណា ដែលបានជាប់ឆ្នោតជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងអាណត្តិមុន ប៉ុន្តែមិនបានជាប់ឆ្នោតឡើងវិញជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងអាណត្តិថ្មីទេ ហើយមិនមាននៅសល់មុខតំណែងផ្សេងទៀតដែលត្រូវជាប់កាតព្វកិច្ចប្រកាសទ្រព្យសម្បត្តិ និងបំណុលទេនោះ សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់រូបនោះ ត្រូវប្រកាសទ្រព្យសម្បត្តិ និងបំណុលក្នុងរង្វង់៣០ថ្ងៃ គិតចាប់ពីថ្ងៃបើកកិច្ចប្រជុំដំបូងដើម្បីប្រកាសសុពលភាពក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិថ្មី។

ឧទាហរណ៍ ក្រុមប្រឹក្សាឃុំ "ខ" បានបើកកិច្ចប្រជុំដំបូងដើម្បីប្រកាសសុពលភាពក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិថ្មី កាលពីថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០១២។ លោក "ឃ" ជាសមាជិកក្រុមប្រឹក្សាឃុំ "ខ" ក្នុងអាណត្តិមុន តែមិនបានជាប់ឆ្នោតជាសមាជិកក្រុមប្រឹក្សាឃុំក្នុងអាណត្តិថ្មីនេះទេ។ ដូច្នេះ លោក "ឃ" ត្រូវប្រកាសទ្រព្យសម្បត្តិ និងបំណុលយ៉ាងយូរបំផុតត្រឹមថ្ងៃទី០២ ខែសីហា ឆ្នាំ២០១២ បន្ទាប់ពីការចាកចេញពីតំណែងសមាជិកក្រុមប្រឹក្សាឃុំ "ខ"។

## ៣. សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ដែលជាប់ឆ្នោតលើកដំបូង

ចំពោះបុគ្គលណាដែលទើបបានឈរឈ្មោះបោះឆ្នោតជ្រើសរើសសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ហើយបានជាប់ឆ្នោតជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់លើកដំបូង ទោះជានៅក្នុងអាណត្តិណានៃក្រុមប្រឹក្សាឃុំ សង្កាត់ក៏ដោយ ហើយមិនធ្លាប់បានប្រកាសទ្រព្យសម្បត្តិ និងបំណុលតាមរយៈមុខតំណែងផ្សេងទេ សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់រូបនោះ ត្រូវប្រកាសទ្រព្យសម្បត្តិ និងបំណុលលើកទី១របស់ខ្លួនក្នុងរង្វង់៣០ថ្ងៃ បន្ទាប់ពីថ្ងៃបើកកិច្ចប្រជុំដំបូងដើម្បីប្រកាសសុពលភាពសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់។

ឧទាហរណ៍ ក្រុមប្រឹក្សាឃុំ "ខ" បានបើកកិច្ចប្រជុំដំបូងដើម្បីប្រកាសសុពលភាពក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិថ្មី កាលពីថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០១២។ លោក "ង" ទើបតែបានជាប់ឆ្នោតជាសមាជិកក្រុមប្រឹក្សាឃុំជាលើកដំបូង សម្រាប់អាណត្តិថ្មីនៃក្រុមប្រឹក្សាឃុំ "ខ"។ រយៈពេលកន្លងមក លោក "ង" មិនធ្លាប់បានប្រកាសទ្រព្យសម្បត្តិ និងបំណុលតាមរយៈមុខតំណែងផ្សេងឡើយ។ ដូច្នេះ លោក "ង" ត្រូវប្រកាសទ្រព្យសម្បត្តិ និងបំណុលលើកទី១របស់ខ្លួន យ៉ាងយូរបំផុតត្រឹមថ្ងៃទី០២ ខែសីហា ឆ្នាំ២០១២។

## ៤. អំពីការផ្លាស់ប្តូរសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់

បន្ទាប់ពីការចូលកាន់តំណែង ជាធម្មតាតែងតែមានសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់មួយចំនួន ត្រូវបានផ្លាស់ប្តូរដូចមានចែងនៅក្នុងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់។ ដូច្នេះ ក្នុងករណីឃុំ សង្កាត់ណាមានការផ្លាស់ប្តូរសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ក្រុមប្រឹក្សាឃុំ ឬសង្កាត់នោះត្រូវណែនាំឲ្យធ្វើការប្រកាសទ្រព្យសម្បត្តិ និងបំណុលរបស់សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ដែលផ្លាស់ប្តូរ ដូចខាងក្រោម ៖

### ក. សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ដែលប្តូរចេញ

ចំពោះសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់រូបណាដែលត្រូវបានប្តូរចេញ ហើយមិនមានសល់មុខតំណែងផ្សេងដែលត្រូវជាប់កាតព្វកិច្ចប្រកាសទ្រព្យសម្បត្តិ និងបំណុលទេ សមាជិករូបនោះត្រូវប្រកាសទ្រព្យសម្បត្តិ និងបំណុលក្នុងរង្វង់៣០ថ្ងៃ មុនការចាកចេញពីមុខតំណែងជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួន។

ឧទាហរណ៍ លោក "ក" ជាសមាជិកក្រុមប្រឹក្សាឃុំ "ខ" ត្រូវបានស្នើសុំប្តូរចេញដោយមូលហេតុបាត់បង់សមាជិកភាពពីគណបក្សនយោបាយ "គ"។ ក្រសួងមហាផ្ទៃបានចេញប្រកាសស្តីពីការប្តូរឈ្មោះ "ក" ចេញពីសមាជិកក្រុមប្រក្សាឃុំ "ខ" នាថ្ងៃទី០១ ខែសីហា ឆ្នាំ២០១២។ ដូច្នេះ ឈ្មោះ "ក" ត្រូវប្រកាសទ្រព្យសម្បត្តិ និងបំណុលយ៉ាងយូរបំផុតត្រឹមថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១២ បន្ទាប់ពីការចាកចេញពីតំណែងសមាជិកក្រុមប្រឹក្សាឃុំ "ខ"។

### ខ. សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ដែលប្តូរចូល

ចំពោះសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់រូបណាដែលត្រូវបានប្តូរចូល ហើយមិនធ្លាប់បានប្រកាសទ្រព្យសម្បត្តិ និងបំណុលតាមរយៈមុខតំណែងផ្សេងទេ សមាជិករូបនោះត្រូវប្រកាសទ្រព្យសម្បត្តិ និងបំណុល ក្នុងរង្វង់៣០ថ្ងៃ បន្ទាប់ចូលកាន់មុខតំណែងជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួន។

ឧទាហរណ៍ លោក "ឃ" ត្រូវបានស្នើសុំប្តូរចូលជាសមាជិកក្រុមប្រឹក្សាឃុំ "ខ" ជំនួសឈ្មោះ "ក" ខាងលើនេះ។ ក្រសួងមហាផ្ទៃបានចេញប្រកាសស្តីពីការប្តូរឈ្មោះ "ឃ" ចូលជាសមាជិកក្រុមប្រឹក្សាឃុំ "ខ" នាថ្ងៃទី០១ ខែសីហា ឆ្នាំ២០១២។ ដូច្នេះ ឈ្មោះ "ឃ" ត្រូវប្រកាសទ្រព្យសម្បត្តិ និងបំណុល យ៉ាងយូរបំផុតត្រឹមថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១២ បន្ទាប់ពីការចូលកាន់តំណែងជាសមាជិកក្រុមប្រឹក្សាឃុំ "ខ"។

## ៥. ការណែនាំបន្ថែម

ក្រុមជំនួយការរបស់ក្រុមជនបង្គោលប្រឆាំងអំពើពុករលួយក្រសួងមហាផ្ទៃផ្នែករដ្ឋបាលស៊ីវិល នៅថ្នាក់រាជធានី ខេត្ត ត្រូវសហការជាមួយអភិបាលក្រុង ស្រុក ខណ្ឌ ជួយណែនាំ និងដាស់តឿនក្រើនរំលឹកដល់សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ទាំងអស់នៅក្នុងរាជធានី ខេត្តរបស់ខ្លួន ឲ្យផុសផុលចូលរួមអនុវត្តការប្រកាសទ្រព្យសម្បត្តិ និងបំណុល។ ឯកសារប្រកាសទ្រព្យសម្បត្តិ និងបំណុលនេះ សាមីខ្លួនអាចផ្ញើមកអង្គភាពប្រឆាំងអំពើពុករលួយតាមរយៈក្រុមជនបង្គោលប្រឆាំងអំពើពុករលួយក្រសួងមហាផ្ទៃផ្នែករដ្ឋបាលស៊ីវិល ឬប្រកាសនៅអង្គភាពប្រឆាំងអំពើពុករលួយដោយផ្ទាល់។ ᚼᚽ

ការខកខានមិនបានប្រកាសទ្រព្យសម្បត្តិ និងបំណុល ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី០១(មួយ)ខែ ទៅ០១(មួយ)ឆ្នាំ និងពិន័យជាប្រាក់ពី១០០.០០០(មួយសែន)រៀល ទៅ២.០០០.០០០(ពីរលាន)រៀល ហើយត្រូវបានបង្ខំឲ្យធ្វើការប្រកាសទ្រព្យសម្បត្តិ និងបំណុលជូនអង្គភាពប្រឆាំងអំពើពុករលួយ ដូចមានចែងក្នុងមាត្រា៣៨ នៃច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ។

ទទួលបានសេចក្តីណែនាំខាងលើនេះ អភិបាលរាជធានី ខេត្ត ក្រុមជនបង្គោលប្រឆាំងអំពើពុករលួយ ក្រសួងមហាផ្ទៃផ្នែករដ្ឋបាលស៊ីវិល និងសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវចាត់ចែងអនុវត្តឲ្យមានប្រសិទ្ធភាពខ្ពស់។

**រដ្ឋមន្ត្រីស្តីទី**

នាយឧត្តមសេនីយ៍ ឯម សំអាន

**ចម្លងជូន**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- អង្គភាពប្រឆាំងអំពើពុករលួយ
- សាលារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ និងសង្កាត់
- ឯកសារ-កាលប្បវត្តិ ៤

សូមសរសេរដោយប៊ិចពណ៌ខៀវ ឬពណ៌ខ្មៅ ឬវាយដោយកុំព្យូទ័រក៏បាន។ បើចាំបាច់អាចសរសេរលើទំព័របន្ថែមបាន។ ទម្រង់នេះអាចបោះពុម្ពចេញពីគេហទំព័រ www.acu.gov.kh ទម្រង់ចេញឆ្នាំ២០១២

# ទម្រង់ប្រកាសទ្រព្យសម្បត្តិ និងបំណុល

ខ្ញុំឈ្មោះ ..........................................ភេទ.............. សូមប្រកាសទ្រព្យសម្បត្តិ និងបំណុលរបស់ខ្ញុំផ្ទាល់ ដែលមានដូចខាងក្រោម៖

## ១. អចលនទ្រព្យ ដូចជាដីធ្លី អគារ លំនៅដ្ឋាន ...

| ឈ្មោះម្ចាស់កម្មសិទ្ធិ[១] | ប្រភេទ[២] | លេខប័ណ្ណកម្មសិទ្ធិ[៣] | ទំហំ[៤] | ទីតាំង | តម្លៃពេលទទួលបាន[៥] | ប្រភពហិរញ្ញវត្ថុ[៦] |
|---|---|---|---|---|---|---|
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |

*សម្គាល់:* *សម្រាប់លេខ [១],[២],[៣],[៤],[៥],[៦] សូមមើលសេចក្តីពន្យល់នៅទំព័រខ្នង*

## ២. <u>យានយន្ត និងគ្រឿងចក្រ</u>

| ប្រភេទ[១] | ម៉ាក និងឆ្នាំផលិត[២] | ផ្លាកលេខ[៣] | តម្លៃពេលទទួលបាន[៤] | **ប្រភពហិរញ្ញវត្ថុ[៥]** |
|---|---|---|---|---|
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |

*<u>សម្គាល់:</u> សម្រាប់លេខ [១],[២],[៣],[៤],[៥] សូមមើលសេចក្តីពន្យល់នៅទំព័រខ្នង*

## ៣. ទ្រព្យសម្បត្តិដែលងាយដោះដូរជាសាច់ប្រាក់

មានគ្រឿងអលង្ការ(ក្រវិល ខ្សែក ខ្សែដៃ ចិញ្ចៀន) និងនាឡិកាដៃដែលមានតម្លៃក្នុងមួយឯកតាចាប់ពី៥លានរៀលឡើងទៅ។

| ប្រភេទ[១] | បរិយាយ[២] | តម្លៃពេលទទួលបាន[៣] | ប្រភពហិរញ្ញវត្ថុ[៤] |
|---|---|---|---|
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |

*សម្គាល់: សម្រាប់លេខ [១],[២],[៣],[៤] សូមមើលសេចក្តីពន្យល់នៅទំព័រខ្នង*

## ៤. សកម្មភាពអាជីវកម្ម - ពាណិជ្ជកម្ម

| ឈ្មោះម្ចាស់អាជីវកម្ម[១] | ប្រភេទ[២] | លិខិតអនុញ្ញាត[៣] | បរិមាណដើមទុនបច្ចុប្បន្ន[៤] | **ប្រភពហិរញ្ញវត្ថុ[៥]** |
|---|---|---|---|---|
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |

*__សម្គាល់:__ សម្រាប់លេខ [១],[២],[៣],[៤],[៥] សូមមើលសេចក្តីពន្យល់នៅទំព័រខ្នង*

## ៥. ការប្រកាសអំពីប្រាក់ (ប្រាក់រៀល រូបិយប័ណ្ណបរទេស មាសដុំ មាសគីឡូ ប្រាក់សុទ្ធ ត្បូង ដែលមិនមែនជាអលង្ការ)

(អង្គភាពប្រឆាំងអំពើពុករលួយសូមបញ្ជាក់ថា មិនមានការចាប់បង្ខំឱ្យប្រកាសពីចំនួនប្រាក់ក្នុង និងក្រៅធនាគារដែលខ្លួនមាននេះទេ។ សាមីខ្លួនចង់ប្រកាសក៏បាន មិនចង់ប្រកាសក៏បាន។ ការមិនប្រកាសប្រាក់រក្សាទុកក្នុងធនាគារមានតម្លៃស្មើនឹងការប្រកាសដែរ ព្រោះធនាគារជាកន្លែងរក្សាប្រាក់ស្របច្បាប់។ រីឯប្រាក់រក្សាទុកក្រៅធនាគារ ប្រសិនបើធ្វើការប្រកាសវាមានផលប្រយោជន៍យកមកធ្វើជាសំអាងស្របច្បាប់សម្រាប់បញ្ជាក់ពីចំណាយផ្សេងៗនៅពេលដែលអង្គភាពប្រឆាំងអំពើពុករលួយសាកសួរ។ ហេតុនេះ ប្រាក់នៅក្រៅធនាគារដែលមិនបានប្រកាសមិនអាចយកមកធ្វើជាសំអាងសម្រាប់បញ្ជាក់ការធ្វើអំណោយ ការទិញអចលនវត្ថុ ចលនវត្ថុ ការទិញ ឬដាក់ទុនធ្វើអ្វីផ្សេងទៀតដែលនាំឱ្យមានកំណើនប្រាក់ និងកំណើនទ្រព្យសម្បត្តិរបស់សាមីខ្លួនបានទេ។)

| ប្រភេទ[១] | បរិមាណ ឬតម្លៃ[២] | ប្រភពហិរញ្ញវត្ថុ[៣] |
|---|---|---|
| | | |
| | | |
| | | |
| | | |
| | | |

*សម្គាល់: សម្រាប់លេខ [១],[២],[៣] សូមមើលសេចក្តីពន្យល់នៅទំព័រខ្នង*

## ៦.ការប្រកាសអំពីបំណុល (គេជំពាក់យើង)

| ឈ្មោះកូនបំណុល[១] | ឈ្មោះម្ចាស់បំណុល[២] | កាលបរិច្ឆេទនៃកម្ចី | បរិមាណបំណុល ដែលបានខ្ចី | បរិមាណបំណុល នៅជំពាក់[៣] | ប្រភពហិរញ្ញវត្ថុ[៤] | ផ្សេងៗ ប្រសិន បើមាន |
|---|---|---|---|---|---|---|
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |

*__សម្គាល់:__ សម្រាប់លេខ [១],[២],[៣],[៤] សូមមើលសេចក្ដីពន្យល់នៅទំព័រខ្នង*

## ៧.ការប្រកាសអំពីចំណូល

| ប្រភពចំណូល[១] | មុខងារ[២] | ចំណូលប្រចាំឆ្នាំ[៣] | ផ្សេងៗបើមាន |
|---|---|---|---|
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |

***សម្គាល់:*** *សម្រាប់លេខ [១],[២],[៣] សូមមើលសេចក្តីពន្យល់នៅទំព័រខ្នង*

## ៨.ការធានាអះអាង

ខ្ញុំសូមធានាអះអាងថា រាល់ព័ត៌មានទាំងអស់ដែលខ្ញុំបានសរសេរក្នុងទម្រង់នេះពិតជាត្រឹមត្រូវ និងពេញលេញទៅតាមព័ត៌មានដែលខ្ញុំមាន។ ខ្ញុំដឹង និងយល់ច្បាស់ថាខ្ញុំអាចប្រឈមមុខនឹងការកាត់ទោសតាមផ្លូវច្បាប់ ប្រសិនបើខ្ញុំមិនបានប្រកាសទ្រព្យសម្បត្តិ និងបំណុល ឬប្រកាសទ្រព្យសម្បត្តិ និងបំណុល មិនត្រឹមត្រូវ។ ខ្ញុំដឹងថាអង្គភាពប្រឆាំងអំពើពុករលួយមានសិទ្ធិទទួលបាននូវព័ត៌មាននានាបន្ថែមទៀតដែលបង្ហាញអំពីទ្រព្យសម្បត្តិ បំណុល និងចំណូលរបស់រូបខ្ញុំ ។

ទោះបីខ្ញុំពឹងពាក់អ្នកណាម្នាក់ឱ្យជួយសរសេរ ឬវាយកុំព្យូទ័រ ឬកាន់ឯកសារនេះមកជូនអង្គភាពប្រឆាំងអំពើពុករលួយក៏ដោយ ប៉ុន្តែខ្ញុំសូមបញ្ជាក់ថា ខ្លឹមសារ ហត្ថលេខា និងស្នាមមេដៃលើឯកសារនេះ ពិតជារបស់ខ្ញុំដោយផ្ទាល់មែន។

ធ្វើនៅ....................ថ្ងៃទី..........ខែ............ឆ្នាំ..............

ហត្ថលេខា ឬស្នាមមេដៃស្តាំ និងឈ្មោះបុគ្គលប្រកាស

ឋានៈ និងតួនាទី:........................................................................................................................................

ក្រសួង ស្ថាប័ន:....................................................អង្គភាព:..........................................នាយកដ្ឋាន:......................

ទីលំនៅបច្ចុប្បន្ន:........................................................................................................................................

---

បំពេញជា២ច្បាប់រួចហើយ (ឬបំពេញតែមួយច្បាប់ ហើយថតចម្លងមួយច្បាប់ទៀតក៏បាន) ត្រូវដាក់ក្នុងស្រោមសំបុត្រពណ៌សចំនួន២ដាច់ដោយឡែកពីគ្នា ហើយផ្តិតមេដៃ (មិនមែនចុះហត្ថលេខាទេ) លើមាត់ស្រោមសំបុត្រដែលបិទជិត (ត្រូវបិទក្រដាសព័ត៌មានផ្ទាល់ខ្លួនរបស់បុគ្គលប្រកាសលើផ្នែកសងខាងស្រោមសំបុត្រក្នុងករណីគ្មានស្រោមសំបុត្រពណ៌សដែលមានបោះពុម្ពស្រាប់) ហើយយកមកប្រគល់ឱ្យអង្គភាពប្រឆាំងអំពើពុករលួយដោយខ្លួនឯង ឬតាមរយៈបុគ្គល ឬក្រុមណាមួយដែលជាតំណាងក្រសួងស្ថាប័ន។

នៅពេលដែលអង្គភាពប្រឆាំងអំពើពុករលួយបានចុះហត្ថលេខា និងវាយត្រាលើមាត់ស្រោមសំបុត្របិទជិតទាំងពីរនោះហើយ អង្គភាពប្រឆាំងអំពើពុករលួយនឹងប្រគល់មួយច្បាប់ទៅសាមីបុគ្គលប្រកាសទ្រព្យសម្បត្តិ និងបំណុល។

| | |
|---|---|
| ប្រកាសចុងក្រោយនៅក្រសួងស្ថាប័ន[១]: .................... <br> ................................................................................ <br> ប្រកាសលើកទី[២]:................................................ | **សម្រាប់មន្ត្រីអង្គភាពប្រឆាំងអំពើពុករលួយបំពេញ** <br> លេខកូដ:.................................................................. ថ្ងៃខែឆ្នាំប្រកាស:.................................. <br> ទីកន្លែងរក្សាទុក:.......................................................... ប្រកាសបន្ទាប់នៅថ្ងៃទី:.......................... |

# ព័ត៌មានផ្ទាល់ខ្លួនរបស់បុគ្គលប្រកាសទ្រព្យសម្បត្តិ និងបំណុល

ក្រសួង ស្ថាប័ន:..........................................................អង្គភាព:..........................................នាយកដ្ឋាន:..................................................

**I.មូលហេតុនៃការប្រកាស:** សូមគូស ☑ នៅក្នុងចំណោមប្រអប់ណាមួយដូចខាងក្រោម៖

| |
|---|
| រូបថត <br> បច្ចុប្បន្នរបស់ <br> បុគ្គលប្រកាស <br> ទំហំ ៤x៦ |

១.☐ការប្រកាសរៀងរាល់២ឆ្នាំម្តង[៣] ២.☐ត្រូវបានទទួលតំណែងថ្មី[៤] ៣.☐លាលែងពីមុខតំណែង ឬចប់អាណត្តិ[៥]

៤.☐បញ្ឈប់ពីមុខតំណែង[៦] ៥.☐ចូលនិវត្តន៍[៧] ៦.☐តាមការកំណត់របស់អង្គភាពប្រឆាំងអំពើពុករលួយ[៨] ៧.☐តម្រូវការស៊ើបអង្កេត[៩]

**II. ក.ព័ត៌មានអំពីបុគ្គលប្រកាស**

១.គោត្តនាម និងនាម: ...............................................................ជាអក្សរឡាតាំង: ...........................................................................

អត្តលេខមន្ត្រីរាជការ: ................................................................... ភេទ: ............ ថ្ងៃខែឆ្នាំកំណើត: ...................................................

២.ទីកន្លែងកំណើត: ..................................................................................................................................................................

៣.សញ្ជាតិ(រៀបរាប់ទាំងអស់): .......................................................................................................ជនជាតិ: ..................................

៤.ឋានៈ និងតួនាទី[១០]: ...................................................................................................................................................

តែងតាំងដោយ[១១]: ...................................................... លេខ: ......................................... ចុះថ្ងៃខែឆ្នាំ: ..............................................

៥.លេខអត្តសញ្ញាណប័ណ្ណប្រជាជន: ...................................................... លេខលិខិតឆ្លងដែន: ..............................................................

៦.អ៊ីម៉ែល: .........................................................លេខទូរស័ព្ទ (រៀបរាប់ទាំងអស់): ......................................................................................

៧.ទីលំនៅបច្ចុប្បន្ន: ...................................................................................................................................................................

*__សម្គាល់:__ សម្រាប់លេខ [(១), (២), (៣), (៤), (៥), (៦), (៧), (៨), (៩), (១០), (១១)] សូមមើលសេចក្តីពន្យល់នៅទំព័រខ្នង*

ទម្រង់ចេញឆ្នាំ២០១២

ប្រកាសចុងក្រោយនៅក្រសួងស្ថាប័ន[១]: ....................
...............................................................................
ប្រកាសលើកទី[២]:....................................................

**សម្រាប់មន្ត្រីអង្គភាពប្រឆាំងអំពើពុករលួយបំពេញ**

លេខកូដ:............................................................................ ថ្ងៃខែឆ្នាំប្រកាស:...................................
ទីកន្លែងរក្សាទុក:............................................................. ប្រកាសបន្ទាប់នៅថ្ងៃទី:..........................

# ព័ត៌មានផ្ទាល់ខ្លួនរបស់បុគ្គលប្រកាសទ្រព្យសម្បត្តិ និងបំណុល

ក្រសួង ស្ថាប័ន:.........................................................អង្គភាព:..............................................នាយកដ្ឋាន:.............................................

**I.មូលហេតុនៃការប្រកាស:** សូមគូស ☑ នៅក្នុងចំណោមប្រអប់ណាមួយដូចខាងក្រោម៖

១.☐ការប្រកាសរៀងរាល់២ឆ្នាំម្តង[៣] ២.☐ត្រូវបានទទួលតំណែងថ្មី[៤] ៣.☐លាលែងពីមុខតំណែង ឬចប់អាណត្តិ[៥]

៤.☐បញ្ឈប់ពីមុខតំណែង[៦] ៥.☐ចូលនិវត្តន៍[៧] ៦.☐តាមការកំណត់របស់អង្គភាពប្រឆាំងអំពើពុករលួយ[៨] ៧.☐តម្រូវការស៊ើបអង្កេត[៩]

រូបថត
បច្ចុប្បន្នរបស់
បុគ្គលប្រកាស
ទំហំ ៤x៦

**II. ក.ព័ត៌មានអំពីបុគ្គលប្រកាស**

១.គោត្តនាម និងនាម: ...........................................................................ជាអក្សរឡាតាំង: ...............................................................................

អត្តលេខមន្ត្រីរាជការ: ................................................................ ភេទ: ............ ថ្ងៃខែឆ្នាំកំណើត: ...............................................................

២.ទីកន្លែងកំណើត: .................................................................................................................................................................................

៣.សញ្ជាតិ(រៀបរាប់ទាំងអស់): ...............................................................................................................ជនជាតិ: .........................................

៤.ឋានៈ និងតួនាទី[១០]: ..........................................................................................................................................................................

តែងតាំងដោយ[១១]: ................................................ លេខ: ...................................... ចុះថ្ងៃខែឆ្នាំ: .......................................................

៥.លេខអត្តសញ្ញាណប័ណ្ណប្រជាជន: .................................................. លេខលិខិតឆ្លងដែន: ...........................................................

៦.អ៊ីម៉ែល: ......................................................លេខទូរស័ព្ទ (រៀបរាប់ទាំងអស់): .......................................................................................

៧.ទីលំនៅបច្ចុប្បន្ន: ...............................................................................................................................................................................

*__សម្គាល់:__ សម្រាប់លេខ (១),(២),(៣),(៤),(៥),(៦),(៧),(៨),(៩),(១០),(១១) សូមមើលសេចក្តីពន្យល់នៅទំព័រខ្នង*

## II. ខ.ព័ត៌មានអំពីស្វាមី ឬភរិយា និងកូនទាំងអស់ (អាចសរសេរលើទំព័របន្ថែម បើចាំបាច់)

| គោត្តនាម និងនាម([1]) | ថ្ងៃខែឆ្នាំកំណើត | សញ្ជាតិ | លេខអត្តសញ្ញាណប័ណ្ណប្រជាជនឬឯកសារមានតម្លៃស្មើ | ឋានៈ និងតួនាទីស្ថាប័នបម្រើការងារ | ទីលំនៅបច្ចុប្បន្ន | លេខទូរស័ព្ទ (រៀបរាប់ទាំងអស់) | មានជាប់ការពាក់ព័ន្ធប្រការ ក្រៅប្រទេស និងជាប់លាប់ឬទេ? |
|---|---|---|---|---|---|---|---|
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |

ទំព័រទាំង២នេះ អាចទាញចេញពីគេហទំព័រ www.acu.gov.kh ហើយអាចបោះពុម្ពមកលើក្រដាសសំបុត្រពណ៌សទំហំ A4

*(សូមបំពេញចំនួន **ពីរច្បាប់** ដោយសរសេរបិចពណ៌ខៀវ ឬពណ៌ខ្មៅ ឬវាយដោយកុំព្យូទ័រក៏បាន)។*

[1] សូមដាក់លេខ (១)ស្វាមី (២)ភរិយា (៣)កូនប្រុស (៤)កូនស្រី នៅចុងឈ្មោះ

***<u>សម្គាល់:</u> សូមមើលគំរូនៃការបំពេញនៅទំព័រខ្នង***